www.ekasar.com

00208

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន
លេខ : ៤០ សគអ

ភ្នំពេញ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ១៩៩៨

# សារាចរ
## អំពី
## ការបិទផ្សព្វផ្សាយលិខិតបទដ្ឋាននានា

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជំរាប លោក លោកស្រី ជាម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់ថា កន្លងទៅក្នុងការចាត់តាំង និងផ្សព្វផ្សាយអនុវត្តច្បាប់ស្ដីពី ការងារ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន បានចេញប្រកាស និងសេចក្ដីជូនដំណឹងជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន បានសង្កេតឃើញថា នៅតាមសហគ្រាស គ្រឹះស្ថានមួយចំនួនធំ កម្មករ-និយោជិត បានធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ដើម្បីជាតំណាងរបស់ខ្លួនរួចហើយដែរ ហើយនៅតាមសហគ្រាស-គ្រឹះស្ថានខ្លះ ទៀត កម្មករ-និយោជិត បានបង្កើតអង្គការសហជីពទៀតផង ។នៅតាមសហគ្រាស គ្រឹះស្ថានជាច្រើន បទបញ្ជាផ្ទៃ ក្នុងត្រូវបានក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ចុះទិដ្ឋាការអោយអនុវត្តជាផ្លូវការ ហើយអនុសញ្ញារួមត្រូវបានចុះហត្ថលេខារវាងនិយោជក និងប្រតិភូបុគ្គលិក ឬ អង្គការសហជីព ។

ទន្ទឹមនិងចំណុចជាវិជ្ជមានទាំងអស់នេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានពិនិត្យ ឃើញថា លិខិតបទដ្ឋាន និងទង្វើទាំងអស់ខាងលើនៅមិនទាន់បានជ្រួតជ្រាបដល់កម្មករ-និយោជិត ទាំងអស់ឡើយ ហើយម្ចាស់ និងនាយក សហគ្រាស គ្រឹះស្ថាន មួយចំនួននៅមិនទាន់បានបង្កលក្ខណៈងាយស្រួលអោយប្រតិភូបុគ្គលិក និងសហជីព បំពេញតួនាទី និងភារកិច្ចស្របច្បាប់របស់ខ្លួនឡើយ ។ កង្វះខាតក្នុងការផ្សព្វផ្សាយជាមូលហេតុសំខាន់ នៃអំពើអសកម្មខាងលើ ហើយដែលបង្កើតឡើងជាបន្តបន្ទាប់នូវវិវាទការងារ ។

ក្នុងគោលបំណងជំរុញការអនុវត្តន៍ច្បាប់ស្ដីពីការងារអោយបានល្អ ក្រសួងសូមធ្វើការណែនាំដូចខាងក្រោមនេះ :

១. ម្ចាស់ និងនាយកគ្រប់សហគ្រាស គ្រឹះស្ថាន ត្រូវរៀបចំអោយមានកន្លែងសមស្របដើម្បីបិទ ផ្សព្វផ្សាយនូវប្រកាស និងសេចក្ដីជូនដំណឹងនានា របស់ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ពិសេសប្រកាសស្ដីពី

www.ekasar.com

ការឈប់សំរាកថ្ងៃបុណ្យដោយមានប្រាក់ឈ្នួល សេចក្តីជូនដំណឹងលេខ ០៦ សកអ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៧ (ចំពោះ សហគ្រាសកាត់ដេរ) ។ល។ សេចក្តីជូនដំណឹង និងសេចក្តីសំរេចផ្សេងៗរបស់សហគ្រាស គ្រឹះស្ថាន ដែលទាក់ទងដល់កម្មករ-និយោជិត អនុសញ្ញារួមរវាងម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងប្រតិភូបុគ្គលិក ឬអង្គការសហជីពជាដើម ។

២.ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានត្រូវផ្តល់កន្លែងសមស្របសំរាប់ប្រតិភូបុគ្គលិក និងអង្គការសហជីព បិទផ្សាយឈ្មោះ រូបថត មុខងាររបស់ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពព្រមទាំងសកម្មភាពរបស់ខ្លួន ។

កន្លែងទាំងពីរខាងលើ ត្រូវស្ថិតក្នុងទីតាំងសមស្រប និងងាយស្រួលសំរាប់ការអានរបស់កម្មករនិយោជិតទាំងអស់ ។

ការរៀបចំអោយមានកន្លែងទាំងពីរខាងលើនេះ រួមទាំងការបិទផ្សាយដូចមានរៀបរាប់ក្នុងចំណុច០១ខាងលើត្រូវអនុវត្តអោយហើយស្រេចក្នុងរយៈពេលយ៉ាងឆាប់បំផុត ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើសារាចរនេះ ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី នឹងអនុវត្តបានល្អតាមសារាចរនេះ ។ / ៤

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

ស៊ុយ សែម

<u>ចម្លងជូន</u> :

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- គ្រប់ក្រសួង "ដើម្បីជ្រាប"
- ក្រសួងព័ត៌មាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍
- រាជកិច្ច
- គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង "ដើម្បីអនុវត្ត"
- បិទផ្សាយនៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន នាយកដ្ឋានអធិការកិច្ចការងារ និងអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ